អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១៥

# សេចក្តីប្រកាសព័ត៌មាន
# អង្គជំនុំជម្រះតុលាការកំពូល
# ចេញដីកាកំណត់កាលបរិច្ឆេទសវនាការលើកទីមួយក្នុងសំណុំរឿង ០០២/០២

អង្គជំនុំជម្រះតុលាការកំពូលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) បានចេញដីកាកំណត់កាលបរិច្ឆេទសវនាការលើកទីមួយទាក់ទងនឹងបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១ ដើម្បីស្តាប់សាក្ខីកម្មរបស់សាក្សីបីរូប ដែលអង្គជំនុំជម្រះបានសម្រេចកោះហៅតាមសេចក្តីសម្រេចចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៥។ សវនាការនេះ គ្រោងនឹងបើកនៅវេលាម៉ោង ០៩ព្រឹក ដល់ម៉ោង ០៤រសៀល នៅថ្ងៃទី ២, ៣, ៦ និង ថ្ងៃទី ៧ ខែ កក្កដា ឆ្នាំ ២០១៥ គឺជាថ្ងៃបម្រុង ប្រសិនបើត្រូវការពេលវេលាបន្ថែម។ សម្រាប់សវនាការបន្ថែមទៀត ដែលត្រូវរួមបញ្ចូលនូវសារណាផ្ទាល់មាត់លើបញ្ហាដែលបានលើកឡើង នៅក្នុងបណ្តឹងសាទុក្ខនោះ អង្គជំនុំជម្រះនឹងធ្វើការកំណត់កាលបរិច្ឆេទទៅតាមពេលវេលាសមស្រប។

សវនាការនេះ ពាក់ព័ន្ធទៅនឹងបណ្តឹងសាទុក្ខរបស់**សហព្រះរាជអាជ្ញា, នួន ជា និង ខៀវ សំផន** ប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿង ០០២/០១ ដែលបានចេញនៅក្នុងខែ សីហា ឆ្នាំ២០១៤។ បណ្តឹងសាទុក្ខនេះ មានទំហំធំធេង និងស្មុគស្មាញ ប្រសិនបើប្រៀបធៀបនឹងកិច្ចដំណើរការនីតិវិធីដទៃទៀត ដែលពាក់ព័ន្ធទៅនឹងអំពើឃោរឃៅដ៏ធ្ងន់ធ្ងរដែលរងការចោទប្រកាន់នោះ។ សារណា ប្រតិចារិកសវនាការ និងភស្តុតាងជាឯកសារនៃសំណុំរឿងដែលជាមូលដ្ឋានសម្រាប់កិច្ចដំណើរការនីតិវិធី មានចំនួនរាប់រយពាន់ទំព័រ។ បន្ថែមលើនេះទៀត ម្ចាស់បណ្តឹងសាទុក្ខ បានលើកឡើងនូវទឡ្ហីករណ៍ជាង ៣៧០ នៅក្នុងបណ្តឹងសាទុក្ខ ដោយរួមបញ្ចូលទាំងបញ្ហាដែលពុំបានកើតឡើងនៅក្នុងសាលក្រមខ្លួនឯងផងដែរ ប៉ុន្តែបានកើតឡើង នៅក្នុងពេលកិច្ចដំណើរការនីតិវិធីជំនុំជម្រះ។ ខុសពីតុលាការព្រហ្មទណ្ឌអន្តរជាតិ និងមានស្តង់ដារអន្តរជាតិដទៃទៀត ដោយយោងតាមវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក បញ្ហាទាំងនេះ ពុំត្រូវបានអនុញ្ញាតឱ្យធ្វើបណ្តឹងសាទុក្ខដាច់ដោយឡែកពីគ្នាឡើយ ប៉ុន្តែ ត្រូវបានអនុញ្ញាតឱ្យលើកឡើងតែនៅពេលបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមប៉ុណ្ណោះ។

សវនាការនឹងបើកទូលាយសម្រាប់សាធារណជន និងតំណាងសារព័ត៌មាន ហើយកន្លែងអង្គុយនៅក្នុងសាលសវនាការនឹងត្រូវចែកជូនដោយគោរពតាមគោលការណ៍ អ្នកមកមុន បានមុន លើកលែងតែកន្លែងអង្គុយ ដែលត្រូវបានរក្សាទុកសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿងនេះ។

ក្នុងករណីដែលពុំទាន់មានការសម្រេចលើបញ្ហានៃបណ្តឹងសាទុក្ខនេះទេ ជនជាប់ចោទនៅតែត្រូវបានសន្មតថាគ្មានទោស។ អង្គជំនុំជម្រះតុលាការកំពូលរំពឹងទុកថា សាធារណៈជន មន្ត្រីរាជការ ប្រព័ន្ធផ្សព្វផ្សាយសារព័ត៌មាន គោរពគោលការណ៍សច្ចធារណ៍នៃនិរទោសនេះ នៅក្នុងសេចក្តីថ្លែងការណ៍ណាមួយដែលខ្លួនមានបំណងធ្វើឡើងស្តីអំពីរឿងក្តីនេះ និងជនជាប់ចោទ។

តំណាងប្រព័ន្ធផ្សព្វផ្សាយដែលមានបំណងចូលរួមក្នុងសវនាការលើបណ្តឹងសាទុក្ខនេះត្រូវមានប័ណ្ណសម្រាប់អ្នកសារព័ត៌មាន និងត្រូវចុះឈ្មោះជាមុន។ សូមអនុវត្តតាមលក្ខខណ្ឌដូចខាងក្រោមដើម្បីស្នើសុំប័ណ្ណព័ត៌មាន៖

ក)អ្នកសារព័ត៌មានដែលមិនទាន់មានប័ណ្ណព័ត៌មានដែលចេញដោយ អ.វ.ត.ក ត្រូវបំពេញទម្រង់បែបបទសុំប័ណ្ណសារព័ត៌មានដោយមានចុះហត្ថលេខា ភ្ជាប់រូបថតទម្រង់ jpg មួយសន្លឹក និងច្បាប់ចម្លងលិខិតឆ្លងដែនមួយច្បាប់ ផ្ញើមកជាមួយសំណើសុំចុះឈ្មោះដើម្បីចូលរួមតាមដានសវនាការលើបណ្តឹងសាទុក្ខ តាមរយៈសារអេឡិចត្រូនិក pas@eccc.gov.kh ។

ខ)អ្នកសារព័ត៌មានដែលមានប័ណ្ណមានសុពលភាពជាផ្លូវការរបស់ អ.វ.ត.ក ត្រូវចុះឈ្មោះដើម្បីចូលរួមតាមដានសវនាការបណ្តឹងសាទុក្ខនៅផ្នែកកិច្ចការសាធារណៈ តាមរយៈការផ្ញើសារអេឡិចត្រូនិកទៅកាន់ pas@eccc.gov.kh ។

គ)អ្នកសារព័ត៌មានដែលមានប័ណ្ណព័ត៌មានជាផ្លូវការរបស់ អ.វ.ត.ក ប៉ុន្តែផុតកំណត់ ត្រូវបំពេញទម្រង់បែបបទសុំប័ណ្ណព័ត៌មានសារជាថ្មី ដោយមានចុះហត្ថលេខាផ្ញើមកជាមួយនឹងសំណើសុំចុះឈ្មោះដើម្បីចូលរួមតាមដានសវនាការបណ្តឹងសាទុក្ខ តាមរយៈសារអេឡិចត្រូនិក pas@eccc.gov.kh ។

សូមកុំភ្លេចបញ្ជាក់លេខប័ណ្ណចាស់ដែលផុតកំណត់ផង !

ទម្រង់បែបបទសម្រាប់សុំប័ណ្ណព័ត៌មាន អាចទាញយកបានពីគេហទំព័ររបស់ អ.វ.ត.ក៖ http://www.eccc.gov.kh/sites/default/files/ECCC_Accreditation_Media_Appl...

***ថ្ងៃផុតកំណត់ឈប់ទទួលការចុះឈ្មោះរបស់អ្នកសារព័ត៌មាន និងសំណើសុំប័ណ្ណព័ត៌មាន៖ ថ្ងៃអង្គារ ទី៣០ ខែមិថុនា ឆ្នាំ ២០១៥ វេលាម៉ោង ៤ រសៀល។***

សំណុំរឿង០០២/០១ គឺជាការជំនុំជម្រះលើកទីមួយនៃការជំនុំជម្រះយ៉ាងតិចពីរប្រឆាំងនឹង ខៀវ សំផន ជាប្រមុខរដ្ឋនៃកម្ពុជាប្រជាធិបតេយ្យ និងនួន ជា អតីតអនុលេខាបក្សកុម្មុយនីស្តកម្ពុជា។ បទចោទនៅក្នុងសំណុំរឿង ០០២/០១ គឺផ្តោតលើបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ដែលរងការចោទប្រកាន់ក្នុងអំឡុងពេលជម្លៀសនៅទីក្រុង

ភ្នំពេញ ក្នុងខែមេសា ឆ្នាំ ១៩៧៥ និង ការផ្លាស់ទីដោយបង្ខំបន្តបន្ទាប់ពីតំបន់ដទៃទៀត រួមទាំង ការកាប់សម្លាប់ដែលរងការចោទប្រកាន់នៅទួលពោធិ៍ជ្រៃ ក្នុងខេត្តពោធិ៍សាត់។ នៅថ្ងៃទី ៧ ខែ សីហា ២០១៤ អង្គជំនុំជម្រះសាលាដំបូងរកឃើញថា ជនជាប់ចោទមានពិរុទ្ធភាពពីបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ និងបានសម្រេចប្រកាសទោសដាក់ពន្ធនាគារជនជាប់ចោទទាំងពីរអស់មួយជីវិត។ នួន ជា និង ខៀវ សំផន បានធ្វើបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ដោយម្នាក់ៗបានលើកទឡ្ហីករណ៍បណ្តឹងសាទុក្ខចំនួន ២២៣ និង ១៤៨ រៀងៗខ្លួន។ បន្ថែមលើនេះ សហព្រះរាជអាជ្ញា បានដាក់បណ្តឹងសាទុក្ខ ដោយកម្រិតត្រឹមតែស្វែងរកដំណោះស្រាយដែលប្រកាសដោយអង្គជំនុំជម្រះតុលាការកំពូល ទាក់ទងនឹងភាពអាចអនុវត្តបាននូវទម្រង់ពង្រីកបន្ថែមនៃសហឧក្រិដ្ឋកម្មរួម ដែលហៅថា “សហឧក្រិដ្ឋកម្មរួមទម្រង់ទី III” (JCE III) នៅចំពោះមុខ អ.វ.ត.ក។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖


**លោក នេត្រ ភក្ត្រា**
មន្ត្រីនាំពាក្យសាលាក្តីខ្មែរក្រហម
ទូរស័ព្ទចល័ត: +៨៥៥ (0) ១២ ៤៨៨ ១៥៦
សារអេឡិចត្រូនិក: neth.pheaktra@eccc.gov.kh

**លោក ឡាស អូលសិន**
មន្ត្រីផ្នែកច្បាប់
ទូរស័ព្ទចល័ត: +៨៥៥ (0) ១២ ៤៨៨ ០២៣
សារអេឡិកត្រូនិក: olsenl@un.org